ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយ
# ស្តីពី
# ចក្ខុវិស័យឧត្តមសិក្សា ២០៣០

មេសា ២០១៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយ
# ស្តីពី
# ចក្ខុវិស័យឧត្តមសិក្សា ២០៣០

មេសា ២០១៤

# មាតិកា

ទំព័រ


បុព្វកថា 1

១. សេចក្តីផ្តើម 2

២. ចក្ខុវិស័យ 4

៣. គោលបំណង 4

៤. គោលដៅ 4

៥. យុទ្ធសាស្ត្រ 4

៦. ផែនការសកម្មភាព 7

៦.១ រចនាសម្ព័ន្ធចាត់ចែង 7

៦.១.១ ឧត្តមក្រុមប្រឹក្សាជាតិអប់រំ 7

៦.១.២ ក្រុមការងារបច្ចេកទេសឧត្តមសិក្សា 8

៦.១.៣ ក្រសួង និងស្ថាប័នអនុវត្តន៍ 8

៦.១.៣.១ ក្រសួងអប់រំ យុវជន និងកីឡា 8

៦.១.៣.២ គ្រឹះស្ថានឧត្តមសិក្សា 8

៦.១.៣.៣ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា 9

៦.១.៣.៤ មាតាបិតា និងនិស្សិត 9

៦.១.៣.៥ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល 9

៦.២ ក្របខណ្ឌច្បាប់ 9

៦.៣ ការគាំទ្រហិរញ្ញវត្ថុ 10

៦.៤ ការអភិវឌ្ឍសមត្ថភាព 10

៦.៥ ការប្រតិបត្តិគម្រោង 10

៦.៦ ការតាមដាន និងការវាយតម្លៃ 11

៧. សេចក្តីសន្និដ្ឋាន 11

# បុព្វកថា

ឧត្តមសិក្សាដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស និងជាអនុវិស័យគន្លឹះមួយ ដែលចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម នៃប្រទេសជាតិនីមួយៗ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកឧត្តមសិក្សា ជាអនុវិស័យមួយដ៏មានសារសំខាន់ក្នុងការអភិវឌ្ឍមូលធនមនុស្សដើម្បីនាំកម្ពុជាឆ្ពោះទៅកាន់ប្រទេស ដែលមានចំណូលមធ្យមកម្រិតខ្ពស់ និងប្រទេសដែលមានចំណូលខ្ពស់នាពេលអនាគត។ ចក្ខុវិស័យវែងឆ្ងាយខាង-លើ របស់រាជរដ្ឋាភិបាល បានឆ្លុះបញ្ចាំងយ៉ាងប្រត្យក្សនៅក្នុងយុទ្ធសាស្ត្រចតុកោណ ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣នេះ។ ជាមួយគ្នានេះ កំណែទម្រង់ជាច្រើនត្រូវបានអនុវត្តឡើងក្នុងទិសដៅលើកកម្ពស់គុណភាព និងសមធម៌នៃការចូលរៀននៅឧត្តមសិក្សាដើម្បីអប់រំនិស្សិតឱ្យមានសមត្ថភាពពេញលេញក្នុងការប្រកួតប្រជែងទាំងផ្នែកសេដ្ឋកិច្ច និងក្នុងការទទួលខុសត្រូវទាំងផ្នែកសង្គម។

សកលភាវូបនីយកម្ម និងសមាហរណកម្មតំបន់មានឥទ្ធិពលយ៉ាងខ្លាំងលើគ្រប់វិស័យនៃសេដ្ឋកិច្ចកម្ពុជា។ ដូចនេះ ការអភិវឌ្ឍឧត្តមសិក្សា ត្រូវសម្របទៅតាមនិន្នាការសកលលោក និងតំបន់។ ឆ្លើយតបទៅនឹងបរិបទនេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគោល-នយោបាយចក្ខុវិស័យឧត្តមសិក្សា២០៣០នេះឡើង ក្នុងគោលបំណងកំណត់ទិសដៅរយៈ-ពេលវែង និងផែនទីបង្ហាញផ្លូវច្បាស់លាស់សម្រាប់អភិវឌ្ឍអនុវិស័យនេះ។

គោលនយោបាយនេះ នឹងធានាសមធម៌និងការចូលរៀនរបស់និស្សិត ប្រសិទ្ធភាព និងភាពរលូននៃការសម្របសម្រួលនិងគ្រប់គ្រងនៅឧត្តមសិក្សា និងយន្តការចាំបាច់នានា ដើម្បីគាំទ្រដល់ប្រព័ន្ធឧត្តមសិក្សា និងការអភិវឌ្ឍធនធានមនុស្ស ដែលនឹងរួមចំណែកពេញលេញដល់ការអភិវឌ្ឍប្រទេសជាតិ។ គោលនយោបាយនេះ ក៏បង្ហាញផងដែរអំពីយុទ្ធសាស្ត្រ និងផែនការសកម្មភាពសំខាន់ៗសម្រាប់អនុវត្តដើម្បីសម្រេចចក្ខុវិស័យនេះដោយជោគជ័យ។

ក្រសួងអប់រំ យុជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបុគ្គល និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមរៀបចំគោលនយោបាយដ៏សំខាន់នេះ។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា គ្រប់ស្ថាប័ន គ្រឹះស្ថានឧត្តមសិក្សា ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធទាំងអស់ បន្តរួមចំណែក និងគាំទ្រដល់ការអនុវត្តគោលនយោបាយចក្ខុវិស័យនេះ ដើម្បីឈានទៅសម្រេចឱ្យបានជោគជ័យក្នុងការអភិវឌ្ឍអនុវិស័យឧត្តមសិក្សាកម្ពុជា ។

រាជធានីភ្នំពេញ ថ្ងៃទី០1 ខែមិថុនា ឆ្នាំ២០១៤

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

# ១. សេចក្តីផ្តើម

តាមទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ិក មូលធនរូបវន្តជាគ្រឹះនៃកំណើនសេដ្ឋកិច្ច។ ប៉ុន្តែ ក្នុងយុគសម័យនៃសេដ្ឋកិច្ចសកល និងវឌ្ឍនភាពនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា កំណើនសេដ្ឋកិច្ច មិនពឹងអាស្រ័យទាំងស្រុងទៅលើមូលធនរូបវន្តតែមួយនោះទេ ពុទ្ធិក៏ដើរតួយ៉ាងសំខាន់ ក្នុងការរួមចំណែកឲ្យមានកំណើនសេដ្ឋកិច្ចផងដែរ។ ការពិត ពុទ្ធិជាមូលធនសកម្ម និងជាប្រភពនៃទ្រព្យធន និងវិបុលភាពទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត។ ឧត្តមសិក្សាដើរតួនាទីសំខាន់បំផុតក្នុងការបង្កើតពុទ្ធិដែលជាមូលធនសកម្មនេះ។ បន្ថែមពីលើតួនាទីចម្បងក្នុងការជម្រុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ឧត្តមសិក្សាក៏នៅមានតួនាទីស្នូល ក្នុងការកសាងពលរដ្ឋសកម្មផងដែរ។ ជាមួយគ្នានេះ ឧត្តមសិក្សាក៏ជាភ្នាក់ងារសកម្មក្នុងការផ្តល់ព័ត៌មានដល់សាធារណជន និងអ្នកធ្វើគោលនយោបាយ អំពីសារសំខាន់នៃវប្បធម៌ សង្គម នយោបាយ និងសេដ្ឋកិច្ច។

បទពិសោធន៍នៃបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍និងអាស៊ីបូព៌ាមួយចំនួនបានបង្ហាញឲ្យឃើញថា វឌ្ឍនភាពនៃការអប់រំ និងការបណ្តុះបណ្តាលនៅកម្រិតឧត្តមសិក្សា ដើរតួនាទីយ៉ាងសំខាន់ក្នុងការនាំមកនូវភាពជោគជ័យនៃការអភិវឌ្ឍប្រទេស ជាពិសេសនៅក្នុងវិស័យឧស្សាហកម្ម តាមរយៈការបង្កើតចំណងទាក់ទង រវាងឧត្តមសិក្សា និង វិស័យឧស្សាហកម្ម ដើម្បីកសាងកម្មវិធីសិក្សា ដែលមានគុណភាពនិងភាពឆ្លើយតបទៅនឹងតម្រូវការ។

នៅកម្ពុជា ការអភិវឌ្ឍឧត្តមសិក្សា ក្រោយសម័យអាណានិគមនិយម បានជួបប្រទះនូវបញ្ហាជាច្រើន ជាពិសេសក្នុងកំឡុងសង្គ្រាមស៊ីវិលជាច្រើនទសវត្សរ៍ និងរបបខ្មែរក្រហម ដែលនៅពេលនោះ វិស័យអប់រំត្រូវបានបំផ្លាញទាំងស្រុង។ ក្នុងកំឡុងទសវត្សរ៍ទី៨០ និង៩០ ប្រព័ន្ធអប់រំកម្ពុជា មិនបានផ្តល់អាទិភាពលើឧត្តមសិក្សាទេ។ ពោលគឺប្រព័ន្ធអប់រំកម្ពុជានៅពេលនោះ បានផ្តោតសំខាន់ទៅលើការកសាងឡើងវិញនូវប្រព័ន្ធអប់រំ និងពង្រឹងការអប់រំចំណេះទូទៅ ពិសេសផ្តោត លើការអប់រំបឋមសិក្សា។

ចាប់តាំងពីចុងទសវត្សរ៍ទី៩០ កំណើនចំនួនសិស្សបញ្ចប់ការសិក្សា នៅមធ្យមសិក្សាទុតិយភូមិ បាននិងកំពុងជម្រុញឲ្យមានកំណើនតម្រូវការសម្រាប់ឧត្តមសិក្សា។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនេះ គោលនយោបាយចម្បងមួយ ត្រូវបានបង្កើតឡើង ដោយផ្អែកទៅលើភាពជាដៃគូ រវាងវិស័យសាធារណៈ និង ឯកជន។ តាមរយៈគោលនយោបាយនេះ គ្រឹះស្ថានឧត្តមសិក្សាឯកជនដំបូង ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៧។ ចាប់តាំងពីពេលនោះមក ចំនួនគ្រឹះស្ថានឧត្តមសិក្សាឯកជនកើនឡើងជាលំដាប់ ជាពិសេសចាប់តាំងពីពាក់កណ្តាល

ឆ្នាំ២០០០ ដែលមានរហូតដល់៦៤ នៅក្នុងឆ្នាំ២០១៤។ ក្នុងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ការសិក្សាបង់ថ្លៃ ត្រូវបានបង្កើតឡើង។ ជាលទ្ធផល ឧត្តមសិក្សានៅកម្ពុជា បានផ្លាស់ប្តូរយ៉ាងខ្លាំង ពីការចូលរៀនដោយសម្រិតសម្រាំង ទៅជាការចូលរៀនដោយទ្រង់ទ្រាយធំ។ ចំនួនគ្រឹះស្ថានឧត្តមសិក្សាសាធារណៈកើនពី៨ នៅឆ្នាំ១៩៩៧ ទៅដល់៣៩ នៅឆ្នាំ២០១៤ និងចំនួននិស្សិតបានកើនពីប្រមាណ ១០ ០០០ នាក់នៅដើមទសវត្សរ៍ទី៩០ ទៅប្រមាណជាង២០០ ០០០ ក្នុងឆ្នាំ២០១៣។

ការវិភាគពីស្ថានភាពឧត្តមសិក្សានាពេលថ្មីៗនេះបង្ហាញពីភាពមិនស៊ីគ្នារវាងការអប់រំ និង ទីផ្សារការងារ។ យោងទៅតាមរបាយការណ៍ផ្សេងៗគ្នា មុខជំនាញសិក្សាដែលមានប្រជាប្រិយភាព ក្នុងចំណោមនិស្សិតកម្ពុជា គឺវិទ្យាសាស្រ្តសង្គម និងមុខវិជ្ជាទាក់ទងនឹងវិស័យធុរកិច្ច។ និស្សិតមួយចំនួនតូចប៉ុណ្ណោះ សិក្សាផ្នែកវិទ្យាសាស្រ្ត បច្ចេកវិទ្យា វិស្វកម្ម និងកសិកម្ម ដែលជាមុខជំនាញគន្លឹះ ដើម្បីជម្រុញការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។ ជាមួយគ្នានេះ គុណភាពនៃឧត្តមសិក្សាកម្ពុជា ក៏ជាបញ្ហាប្រឈមដ៏សំខាន់ផងដែរ។

បន្ថែមពីលើនេះ ការផ្លាស់ប្តូរថ្មីៗនៃរចនាសម្ព័ន្ធសង្គម សេដ្ឋកិច្ចកម្ពុជា កម្មវិធីពង្រីកសមត្ថភាពឧស្សាហកម្ម ដំណើរការសមារហរណកម្មអាស៊ាន និងការដាក់ចេញចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ ទាមទារជាបន្ទាន់ឲ្យមានការធ្វើកំណែទម្រង់ និងការពង្រីកសមត្ថភាពវិស័យឧត្តមសិក្សា ដើម្បីធានាឲ្យបានថា យុវជនត្រូវបានបំពាក់ដោយជំនាញចាំបាច់ ដើម្បីលើកកម្ពស់ស្តង់ដារនៃការរស់នៅ និងរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ។ ក្នុងបរិបទនេះ ក្រសួងអប់រំ យុវជន និងកីឡា រៀបចំចក្ខុវិស័យសម្រាប់ការអភិវឌ្ឍអនុវិស័យឧត្តមសិក្សារយៈពេលវែង ឲ្យស្របនឹងចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០។

## ២. ចក្ខុវិស័យ

កសាងប្រព័ន្ធឧត្តមសិក្សាមួយប្រកបដោយគុណភាព ដើម្បីអភិវឌ្ឍធនធានមនុស្ស ឱ្យមានចំណេះដឹង ជំនាញ និងសីលធម៌ខ្ពស់ សម្រាប់ធ្វើការងារនិងរស់នៅ ក្នុងយុគសម័យ នៃសកលភាវូនីយ៍កម្ម និងសង្គមពុទ្ធិ។

## ៣. គោលបំណង

អភិវឌ្ឍប្រព័ន្ធអភិបាលកិច្ចល្អ និងយន្តការឧត្តមសិក្សា ដើម្បីធានាថា និស្សិតដែល មានសមត្ថភាព មានកាលានុវត្តភាពចូលរៀននៅក្នុងកម្មវិធីប្រកបដោយគុណភាព នៃឧត្តម-សិក្សា ដែលឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងទីផ្សារការងារ។

## ៤. គោលដៅ

៤.១. បង្កើតកម្មវិធីសមធម៌ និងការចូលរៀនឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីធានាថា និស្សិត ដែលមានសមត្ថភាព មានកាលានុវត្តភាពចូលរៀននៅឧត្តមសិក្សា និងបញ្ចប់សិក្សា ប្រកបដោយគុណភាព និងគុណធម៌ខ្ពស់។

៤.២. អភិវឌ្ឍកម្មវិធីសិក្សាដែលមានភាពឆ្លើយតប ដើម្បីផ្តល់ឱ្យនិស្សិតនូវចំណេះដឹង និង ជំនាញ ដែលជួយពួកគេឱ្យចូលរួមចំណែកពេញលេញដល់តម្រូវការ នៃការអភិវឌ្ឍ ជាតិ និងទីផ្សារការងារ។

៤.៣. លើកកម្ពស់គុណភាពនៃការរៀន ការបង្រៀន និងការស្រាវជ្រាវ ដើម្បីផ្តល់ឱ្យនិស្សិត នូវចំណេះដឹង និងជំនាញ ដែលជាតម្រូវការនៃទីផ្សារការងារ និងរួមចំណែកដល់ ការអភិវឌ្ឍជាតិ។

៤.៤. អភិវឌ្ឍប្រព័ន្ធអភិបាលកិច្ច យន្តការនានា និងគោលនយោបាយសម្រាប់ឧត្តមសិក្សា ដើម្បីលើកកម្ពស់គុណភាពនៃការគ្រប់គ្រង និងសមិទ្ធកម្មនៃគ្រឹះស្ថានឧត្តមសិក្សា និង ស្ថាប័នពាក់ព័ន្ធដទៃទៀត។

## ៥. យុទ្ធសាស្ត្រ

**៥.១. ធានាថា និស្សិតដែលមានសមត្ថភាព មានកាលានុវត្តភាពចូលរៀននៅឧត្តមសិក្សា ដោយមិនគិត អំពីស្ថានភាពសេដ្ឋកិច្ច ឬសង្គមរបស់ពួកគេ។**

៥.១.១. ធានាថាកម្មវិធីសិក្សា និងប្រព័ន្ធប្រឡងនៃមធ្យមសិក្សាទុតិយភូមិ កំណត់

បាន នូវនិស្សិតដែលមានសមត្ថភាព ដើម្បីចូលរៀននៅឧត្តមសិក្សា។

៥.១.២. ពង្រីកការចូលរៀនប្រកបដោយសមធម៌ នៅឧត្តមសិក្សា សម្រាប់និស្សិតដែលមានសមត្ថភាព ដោយរាប់បញ្ចូលទាំងនិស្សិតក្រីក្រ និស្សិតនារី និស្សិតតំបន់ដាច់ស្រយាល និងនិស្សិតបាត់បង់សមត្ថភាព តាមរយៈកម្មវិធីអាហារូបករណ៍ជាតិ។

៥.១.៣. ពង្រឹង សមត្ថភាពនាយកដ្ឋានឧត្តមសិក្សា សម្រាប់ទទួលខុសត្រូវលើការអនុវត្ត និងការពិនិត្យតាមដាន នូវកម្មវិធីនានា ដែលជួយសម្រួលដល់ការចូលរៀនរបស់និស្សិតក្រីក្រ និស្សិតនារី និស្សិតតំបន់ដាច់ស្រយាល និងនិស្សិតបាត់បង់សមត្ថភាព នៅក្នុងឧត្តមសិក្សាកម្ពុជា។

**៥.២. ធានាថា គ្រប់គ្រឹះស្ថានឧត្តមសិក្សា ផ្តល់ឱ្យនិស្សិតនូវកម្មវិធីសិក្សា ដែលមានគុណភាព និងឆ្លើយតបទៅនឹងតម្រូវការ និងអាទិភាពរបស់ជាតិ។**

៥.២.១. បង្កើតកម្មវិធីអាហារូបករណ៍គ្រប់ជ្រុងជ្រោយមួយ ដើម្បីគាំទ្រដល់និស្សិតដែលមានសមត្ថភាព ប៉ុន្តែខ្វះលទ្ធភាពហិរញ្ញវត្ថុ។

៥.២.២. ពង្រីកកម្មវិធីផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា ឱ្យឆ្លើយតបទៅនឹងគោលបំណង និងគោលដៅនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

**៥.៣. ធានាថា ប្រព័ន្ធឧត្តមសិក្សាកម្ពុជា ពង្រីកកាលានុវត្តភាព សម្រាប់និស្សិតដែលមានសមត្ថភាព ឱ្យបានចូលរៀនពេញមួយជីវិត និងអភិវឌ្ឍវិជ្ជាជីវៈ។**

៥.៣.១. ផ្តល់អាជ្ញាប័ណ្ណឱ្យប្រតិបត្តិចំពោះតែគ្រឹះស្ថានឧត្តមសិក្សា ដែលមានសមត្ថភាព បង្ហាញពីហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស ភាពរឹងមាំនៃហិរញ្ញវត្ថុ រចនាសម្ព័ន្ធគ្រប់គ្រង ផែនការអភិវឌ្ឍន៍ និងដំណើរការធានាគុណភាពផ្ទៃក្នុងសមស្របដែលធានាថា កម្មវិធីដែលផ្តល់ឱ្យនិស្សិត មានគុណភាពខ្ពស់។

៥.៣.២. កសាងសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សា ឱ្យឆ្លើយតបទៅនឹងស្តង់ដារជាតិនៃអភិបាលកិច្ច និងការគ្រប់គ្រង ដោយផ្អែកលើគោលការណ៍តំបន់ និងអន្តរជាតិ។

៥.៣.៣. អភិវឌ្ឍស្តង់ដារអប្បបរមា ដើម្បីធ្វើឱ្យកម្មវិធីបណ្តុះបណ្តាលនិស្សិត ទាំងកម្រិតបរិញ្ញាបត្រ និងក្រោយបរិញ្ញាបត្រ អាចប្រៀបធៀបបានជាមួយនឹងស្តង់ដារតំបន់ និងអន្តរជាតិ។

៥.៤. ធានាថា គ្រឹះស្ថានឧត្តមសិក្សា អភិវឌ្ឍប្រព័ន្ធធានាគុណភាព ឱ្យឆ្លើយតបទៅនឹងស្តង់ដារទទួលស្គាល់គុណភាពថ្នាក់ជាតិ និងអាចចូលរួមពេញលេញ នៅក្នុងប្រព័ន្ធសកលនៃការធានាគុណភាពឧត្តមសិក្សា។

៥.៤.១. អភិវឌ្ឍផែនការ ដើម្បីលើកកម្ពស់សមត្ថភាពជំនាញវិជ្ជាជីវៈ សម្រាប់មន្ត្រីអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ដើម្បីធានាថា ដំណើរការនៃការធានាគុណភាព ដែលត្រូវបានអនុវត្ត ចំពោះគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ឱ្យមានសង្គតិភាពជាមួយនឹងស្តង់ដារតំបន់ និងអន្តរជាតិ។

៥.៤.២. ជម្រុញការរៀបចំកម្មវិធីផ្លាស់ប្តូរនិងកម្មវិធីភ្លោះជាមួយនឹងសាកលវិទ្យាល័យបរទេសល្បីឈ្មោះ ដើម្បីជួយលើកកម្ពស់សមត្ថភាពមន្ត្រី និងលើកកម្ពស់ការរៀន ការបង្រៀន និងការស្រាវជ្រាវ។

៥.៥. ធានាថា បុគ្គលិកបង្រៀន និងនិស្សិត ជាពិសេសនិស្សិតក្រោយបរិញ្ញាបត្រ នឹងចូលរួមចំណែកដល់ការលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ និងការអភិវឌ្ឍ នៅកម្ពុជា ដើម្បីបម្រើឱ្យសេចក្តីត្រូវការនៃការអភិវឌ្ឍជាតិ។

៥.៥.១. លើកទឹកចិត្តដល់គ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកបង្រៀន ដើម្បីអភិវឌ្ឍការស្រាវជ្រាវ និងសេវាពិគ្រោះយោបល់ ដែលពង្រឹង និងមានប្រយោជន៍ដល់វប្បធម៌ខ្មែរ ការកំណត់តម្រូវការជំនាញ និងអាទិភាពនៃការអភិវឌ្ឍជាតិ។

៥.៥.២. កសាងប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈ និងអាជីពការងាររបស់បុគ្គលិក ឱ្យបានគ្រប់ជ្រុងជ្រោយ ដែលលើកទឹកចិត្តក្នុងការរៀន ការបង្រៀន ការស្រាវជ្រាវ និងការគ្រប់គ្រង ឱ្យកាន់តែប្រសើរ។

៥.៦. ធានាថា និស្សិតបញ្ចប់ការសិក្សា ទទួលបានចំណេះដឹង និងជំនាញ ដែលអាចឱ្យពួកគេរួមចំណែកពេញលេញ ដល់ការអភិវឌ្ឍជាតិក្នុងការផ្លាស់ប្តូរបរិយាការដ៏ឆាប់រហ័ស។

៥.៦.១. គ្រឹះស្ថានឧត្តមសិក្សា ត្រូវធានាថា ការអភិវឌ្ឍកម្មវិធី ត្រូវបានបញ្ចូលជំនាញនៃការគិតប្រកបដោយការពិចារណា ការវិភាគ និងភាពដឹកនាំ។

៥.៦.២. គ្រឹះស្ថានឧត្តមសិក្សា ត្រូវធានាថា ការអភិវឌ្ឍកម្មវិធីសិក្សាគ្រប់ដេប៉ាតឺម៉ង់ត្រូវបញ្ចូលការអនុវត្តជាក់ស្តែង ដែលផ្សារភ្ជាប់ទៅនឹងតម្រូវការនៃទីផ្សារការងារ។

៥.៦.៣ គ្រឹះស្ថានឧត្តមសិក្សា ត្រូវបញ្ចូលកម្មវិធីអប់រំបន្តពេញមួយជីវិត ដោយផ្អែកលើក្រេឌីតសិក្សា នៅក្នុងកម្មវិធីបណ្តុះបណ្តាល សម្រាប់ការអភិវឌ្ឍបុគ្គលិក និងវិជ្ជាជីវៈ។

៥.៧. ធានាថា គ្រប់កម្មវិធីសិក្សា ត្រូវបានអភិវឌ្ឍ ដោយផ្អែកលើការវិភាគនៃការបណ្តុះ-បណ្តាលថ្នាក់ជាតិ និងតម្រូវការជំនាញ។

៥.៧.១. ពង្រឹងប្រព័ន្ធធ្វើផែនការ ហិរញ្ញប្បទាន ការពិនិត្យតាមដាន ការពិនិត្យឡើង-វិញ និងរបាយការណ៍នៅឧត្តមសិក្សា

៥.៧.២. អភិវឌ្ឍផែនការដើម្បីលើកកម្ពស់អភិបាលកិច្ចនិងការគ្រប់គ្រងនៅឧត្តមសិក្សា

៥.៧.៣. អភិវឌ្ឍផែនការសម្រាប់បង្កើតសាកលវិទ្យាល័យ "គំរូ" នៅកម្ពុជា ដែលមានស្វ័យភាព និងគុណភាពខ្ពស់។

៥.៨. ធានាថា ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសម្របសម្រួល និងសហការគ្នា ដើម្បីពង្រីកជាអតិបរមានូវផលប៉ះពាល់នៃឧត្តមសិក្សា ដល់ការអភិវឌ្ឍសេដ្ឋកិច្ច ឧស្សាហកម្ម ពាណិជ្ជកម្ម កសិកម្ម សង្គម និងវប្បធម៌របស់កម្ពុជា។

៥.៨.១. ធានាថា ក្រុមប្រឹក្សាភិបាលត្រូវមានការទទួលខុសត្រូវលើសមិទ្ធកម្មរួមរបស់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជន ត្រូវតែគិតគូ ពីផលប្រយោជន៍របស់អ្នកពាក់ព័ន្ធ និងផ្សារភ្ជាប់គ្រឹះស្ថានឧត្តមសិក្សា ទៅនឹងស្ថាប័នជាតិ ស្ថាប័នវិជ្ជាជីវៈ និងស្ថាប័នឧស្សាហកម្មពាក់ព័ន្ធ។

៥.៨.២. ធានាថា អភិបាលកិច្ចនិងការគ្រប់គ្រង នៃប្រព័ន្ធឧត្តមសិក្សាកម្ពុជា និងគ្រឹះស្ថានឧត្តមសិក្សានីមួយៗ ឆ្លើយតបទៅនឹងស្តង់ដារតំបន់និងអន្តរជាតិ។

## ៦. ផែនការសកម្មភាព

ដើម្បីសម្រេចយុទ្ធសាស្ត្រខាងលើ មានសកម្មភាពជាច្រើនដែលត្រូវអនុវត្តៈ

### ៦.១. រចនាសម្ព័ន្ធចាត់ចែង

ដើម្បីសម្រេចបាននូវការគ្រប់គ្រង និងការអនុវត្តនៃគោលនយោបាយនេះ ទាមទារនូវយន្តការបីកម្រិតៈ ១) ឧត្តមក្រុមប្រឹក្សាជាតិអប់រំ ២) ក្រុមការងារបច្ចេកទេសឧត្តមសិក្សា និង ៣) ក្រសួងនិងស្ថាប័នពាក់ព័ន្ធ គ្រឹះស្ថានឧត្តមសិក្សា មាតាបិតានិងនិស្សិត និងដៃគូអភិវឌ្ឍន៍។ ការទទួលខុសត្រូវលម្អិតនៃកម្រិតនីមួយៗ មានរៀបរាប់ខាងក្រោមៈ

#### ៦.១.១. ឧត្តមក្រុមប្រឹក្សាជាតិអប់រំ

ផ្អែកលើច្បាប់ស្តីពីការអប់រំ មាត្រា៥ ឧត្តមក្រុមប្រឹក្សាជាតិអប់រំមានភារកិច្ចៈ ១) លើកសំណើគោលនយោបាយអប់រំ និងយុទ្ធសាស្ត្ររយៈពេលវែង សំដៅឆ្លើយតបនឹងសំណូមពរអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចរបស់ប្រទេសជាតិ ជូនរាជរដ្ឋាភិបាល ២) វាយតម្លៃការងារ ដែលពាក់ព័ន្ធនឹងវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមកាលកំណត់ជូនរាជ-រដ្ឋាភិបាល និង ៣) កៀគរគ្រប់ធនធានដើម្បីបម្រើបុព្វហេតុអប់រំ។

### ៦.១.២. ក្រុមការងារបច្ចេកទេសឧត្តមសិក្សា

ក្រុមការងារបច្ចេកទេសឧត្តមសិក្សា មានការទទួលខុសត្រូវចម្បង គឺការលើកកម្ពស់ប្រសិទ្ធភាពជំនួយ និងដៃគូអភិវឌ្ឍន៍ ក្នុងការគាំទ្រលើសមិទ្ធផលនៃគោលនយោបាយឧត្តម-សិក្សា។ ក្រសួងអប់រំ យុវជន និងកីឡា ជាប្រធាន និងក្រសួងពាក់ព័ន្ធ ជាសមាជិកនៃក្រុមការងារបច្ចេកទេសនេះ។

### ៦.១.៣. ក្រសួង និងស្ថាប័នអនុវត្តន៍

#### ៦.១.៣.១. ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា មានតួនាទីសំខាន់នៃការសម្របសម្រួល ក្នុងចំណោមក្រសួងពាក់ព័ន្ធ ស្ថាប័នជាតិ គ្រឹះស្ថានឧត្តមសិក្សា វិស័យឯកជន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ដើម្បីបំលែងគោលនយោបាយចក្ខុវិស័យឧត្តមសិក្សា២០៣០ ឲ្យក្លាយទៅជាផែនការយុទ្ធសាស្ត្រឧត្តមសិក្សា និងផែនការសកម្មភាព និងផ្តល់បរិយាកាសល្អក្នុងការអនុវត្តផែនការទាំងពីរ ក្នុងស្មារតីសហប្រតិបត្តិការ។

#### ៦.១.៣.២. គ្រឹះស្ថានឧត្តមសិក្សា

គ្រឹះស្ថានឧត្តមសិក្សាមានតួនាទីដូចខាងក្រោមៈ

ក) អភិវឌ្ឍ បេសកកម្ម ផែនការយុទ្ធសាស្ត្រ និង ផែនការអភិវឌ្ឍសមត្ថភាពរបស់គ្រឹះស្ថានឧត្តមសិក្សាឲ្យមានសង្គតភាពជាមួយនឹងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព របស់ឧត្តមសិក្សា។

ខ) បង្កើតយន្តការធានាគុណភាពផ្ទៃក្នុង និងធ្វើការស្វ័យវាយតម្លៃផ្ទៃក្នុងឲ្យបានទៀង-ទាត់លើការគ្រប់គ្រង និងកម្មវិធីបណ្តុះបណ្តាល ដោយផ្អែកតាមលិខិតបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

គ) ដាក់របាយការណ៍ស្វ័យវាយតម្លៃជូនគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា សម្រាប់ការទទួលស្គាល់គុណភាព។ ពង្រឹង ប្រព័ន្ធពិនិត្យតាមដាន នៅក្នុងក្របខណ្ឌពិនិត្យតាមដានរបស់ឧត្តមសិក្សា និងរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ហើយដាក់ជូនក្រសួងអប់រំ យុវជន និងកីឡា។

ឃ) ចូលរួម ក្នុងដំណើរការរៀបចំ និងពិនិត្យឡើងវិញ នូវផែនការប្រតិបត្តិប្រចាំឆ្នាំសម្រាប់ឧត្តមសិក្សា។

ង) ពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម នៅក្នុងគ្រឹះស្ថានឧត្តមសិក្សា ដើម្បីធានាការប្រើធនធាន ឲ្យបានត្រឹមត្រូវ សម្រាប់លើកកម្ពស់គុណភាព នៃកម្មវិធីបណ្តុះបណ្តាល។

ច) ពង្រឹងរចនាសម្ព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងធនធានមនុស្ស និងធានាឲ្យបាន

នូវសមត្ថភាពដ៏មានប្រសិទ្ធភាព ដើម្បីប្រើសិទ្ធិអំណាចដែលទទួលបានក្រោមក្របខណ្ឌនៃស្វ័យភាព និងគណនេយ្យភាព របស់គ្រឹះស្ថានឧត្តមសិក្សា។

ឆ) កសាងកម្មវិធីសិក្សាភ្លោះ ឬបណ្ដាញ ជាមួយគ្រឹះស្ថានឧត្តមសិក្សាក្រៅប្រទេស និងសហការជាមួយវិស័យឯកជន។

ជ) ជម្រុញសកម្មភាពស្រាវជ្រាវ ដែល ១) គាំទ្រដល់ការលើកកម្ពស់គុណភាពនៃការបង្រៀន និងការរៀន ២) ផ្ដោតលើប្រធានបទអាទិភាព ៣) ដោះស្រាយបញ្ហាអភិវឌ្ឍន៍ជាក់ស្តែង ៤) នាំឲ្យមានការកើនឡើងនៃការរីកចម្រើនសេដ្ឋកិច្ច។

### ៦.១.៣.៣. គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា មានភារកិច្ចដូចខាងក្រោម៖

ក) បង្កើត និងអនុវត្តនូវប្រព័ន្ធទទួលស្គាល់គុណភាពឧត្តមសិក្សា។

ខ) សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការអភិវឌ្ឍ និងការអនុវត្តប្រព័ន្ធទទួលស្គាល់គុណ ភាព ។

គ) ធ្វើការវាយតម្លៃពីខាងក្រៅ លើសមិទ្ធកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា ធៀបនឹងស្តង់ដារអប្បបរមា និង បង្ហាញលទ្ធផលនៃការវាយតម្លៃ តាមរយៈគេហទំព័រសម្រាប់ជាពត៍មានដល់សាធារណជន។

ឃ) ជាសមាជិកនៃក្រុមការងារបច្ចេកទេសឧត្តមសិក្សា។

### ៦.១.៣.៤. មាតាបិតា និងនិស្សិត

មាតាបិតានិងនិស្សិត មានសិទ្ធិក្នុងការសម្តែងមតិលើការងារឧត្តមសិក្សា ដើម្បីលើកកម្ពស់គុណភាព នៃកម្មវិធីបណ្ដុះបណ្ដាល។ ពួកគាត់មានសិទ្ធិ ក្នុងការទទួលបានព័ត៌មានសិក្សា និងកំណត់ត្រាពីគ្រឹះស្ថានឧត្តមសិក្សាពាក់ព័ន្ធ។

### ៦.១.៣.៥. ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល

ដៃគូអភិវឌ្ឍន៍រាប់ទាំងអង្គការសង្គមស៊ីវិល ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់ប្រតិបត្តិផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាពឧត្តមសិក្សា និងជាសមាជិកនៃក្រុមការងារបច្ចេកទេសឧត្តមសិក្សា។

## ៦.២. ក្របខណ្ឌច្បាប់

ច្បាប់ស្តីពីការអប់រំ ផ្តល់នីត្យានុកូលភាពពេញលេញសម្រាប់អនុវិស័យឧត្តមសិក្សា។ ការប្រតិបត្តិនៃគោលនយោបាយចក្ខុវិស័យឧត្តមសិក្សា២០៣០ ត្រូវតែធ្វើតាមនីត្យានុកូលភាពទាំងនោះដែលរាប់ទាំង ការអភិវឌ្ឍផែនការយុទ្ធសាស្រ្តឧត្តមសិក្សា ផែនការសកម្មភាពឧត្តមសិក្សា បទដ្ឋានគតិយុត្តិ គោលការណ៍ គោលនយោបាយប្រតិបត្តិ និងនីតិវិធី។

### ៦.៣. ការគាំទ្រហិរញ្ញវត្ថុ

ការអភិវឌ្ឍឧត្តមសិក្សា ទាមទារឲ្យមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ និងការប្រើប្រាស់ធនធានទាំងនោះឲ្យមានប្រសិទ្ធភាព ដើម្បីជម្រុញការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រឧត្តមសិក្សា។ ក្នុងបរិបទបច្ចុប្បន្ននៃឧបសគ្គហិរញ្ញវត្ថុ អនុវិស័យឧត្តមសិក្សា ត្រូវផ្តោតទៅលើអន្តរាគមន៍នវានុវត្តន៍គន្លឹះនៅក្នុងកំឡុងពេល៥ឆ្នាំទៅមុខ ដែលទាមទារឱ្យមានការប្រើប្រាស់ធនធានហិរញ្ញវត្ថុ កាន់តែមានប្រសិទ្ធភាពថែមទៀត។ អន្តរាគមន៍ទាំងនោះអាចរាប់បញ្ចូលៈ

ក) ពង្រឹងប្រព័ន្ធស្វ័យភាព គណនេយ្យភាព និងគ្រប់គ្រងហិរញ្ញវត្ថុ នៃគ្រឹះស្ថានឧត្តមសិក្សា ដែលធានាឱ្យបាននូវការប្រើប្រាស់ធនធានទាំងនោះសម្រាប់លើកកម្ពស់គុណភាព នៃកម្មវិធីបណ្តុះបណ្តាលនៅឧត្តមសិក្សា។ អន្តរាគមន៍នេះ មិនត្រឹមតែបង្កើនចំនួននិស្សិត ឱ្យចូលរៀននៅឧត្តមសិក្សាទេ ក៏ប៉ុន្តែ វាបង្កើនចំណូលរបស់គ្រឹះស្ថានឧត្តមសិក្សា និងអប់រំនិស្សិតឱ្យមានជំនាញប្រកបដោយគុណភាពខ្ពស់។

ខ) ពង្រឹងសកម្មភាព និងសមត្ថភាព នៃការស្រាវជ្រាវនិងនវានុវត្តន៍ ដែលនឹងមានឥទ្ធិពលផ្ទាល់ទៅនឹងសមត្ថភាពរបស់និស្សិតបញ្ចប់ការសិក្សា ដើម្បីឈានចូលទៅក្នុងទីផ្សារការងារ ដែលមានការផ្លាស់ប្តូរជានិច្ច ក៏ដូចជាបង្កើតធនធានហិរញ្ញវត្ថុសម្រាប់គ្រឹះស្ថានឧត្តមសិក្សា ពីដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។ របកគំហើញនៃសកម្មភាពស្រាវជ្រាវ និងនវានុវត្តន៍ទាំងនោះ នឹងចូលរួមចំណែកដល់ការរីកលូតលាស់ នៃសេដ្ឋកិច្ចផងដែរ។

គ) ពង្រឹងប្រព័ន្ធឧត្តមសិក្សា ក្នុងការធ្វើផែនការ ការធ្វើនិយ័តកម្ម និងការគាំទ្រដល់ការអភិវឌ្ឍ អភិបាលកិច្ច ការពិនិត្យតាមដាននិងការពិនិត្យឡើងវិញ ការគ្រប់គ្រងហិរញ្ញវត្ថុ និងការធ្វើរបាយការណ៍របស់គ្រឹះស្ថានឧត្តមសិក្សា។

ឃ) កសាងសមត្ថភាពឧត្តមសិក្សា ដើម្បីស្រូបយកធនធានហិរញ្ញវត្ថុបន្ថែមទៀត ពីចំណូលសាធារណៈ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល។

### ៦.៤. ការអភិវឌ្ឍសមត្ថភាព

ដើម្បីធានាដល់ការប្រតិបត្តិប្រកបដោយប្រសិទ្ធភាព នៃគោលនយោបាយចក្ខុវិស័យឧត្តមសិក្សា២០៣០ វាទាមទារឲ្យមានធនធានមនុស្ស ដែលមានសមត្ថភាព ទាំងនៅក្នុងផ្នែកនៃការដឹកនាំនិងការគ្រប់គ្រង ការបង្រៀននិងការស្រាវជ្រាវ ការធ្វើផែនការ និងការវិភាគទិន្នន័យ។

### ៦.៥ ការប្រតិបត្តិគម្រោង

ក្រសួងអប់រំ យុវជន និងកីឡា នឹងពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ដើម្បីអភិវឌ្ឍគម្រោងវិនិយោគឧត្តមសិក្សា នៅក្នុងក្របខណ្ឌនៃគោលនយោបាយចក្ខុវិស័យឧត្តមសិក្សា២០៣០។ ក្រសួងអប់រំ យុវជន និងកីឡា ទទួលខុសត្រូវលើការអនុវត្ត និងការគ្រប់គ្រងគម្រោងនេះ។

### ៦.៦ ការតាមដាន និងការវាយតម្លៃ

ដើម្បីធានាថា គោលនយោបាយនេះត្រូវបានអនុវត្តប្រកបដោយជោគជ័យ វាចាំបាច់ត្រូវមានប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ដែលផ្តោតទៅលើសមិទ្ធផលនៃ៖

- ទិសដៅ និងយុទ្ធសាស្ត្រ នៅក្នុងផែនការយុទ្ធសាស្ត្រឧត្តមសិក្សា
- សូចនាករ នៅក្នុងផែនការយុទ្ធសាស្ត្រឧត្តមសិក្សា
- លទ្ធផលធៀបនឹងទិសដៅ។

## ៧. សេចក្តីសន្និដ្ឋាន

សមិទ្ធផល និងការធ្វើឱ្យរឹងមាំ នៃការអប់រំបឋមសិក្សានិងមធ្យមសិក្សា ការផ្លាស់ប្តូរនៅក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ច និងតម្រូវការទីផ្សារការងារ ជាមួយគ្នានឹង តម្រូវការសម្រាប់សមាហរណកម្មតំបន់និងសកលលោក បានទាមទារឲ្យកម្ពុជា ពិនិត្យឡើងវិញនូវអនុវិស័យឧត្តមសិក្សារបស់ខ្លួន។ ក្នុងបរិបទនេះ ឧត្តមសិក្សា ត្រូវបានផ្តល់អាទិភាពច្រើនជាង នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៤-២០១៨ បើធៀបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំលើកមុនៗ។ អាទិភាពថ្មី ដែលត្រូវបានផ្តល់ដល់អនុវិស័យឧត្តមសិក្សា ស្ថិតនៅក្នុងយុទ្ធសាស្ត្រនៃការអភិវឌ្ឍធនធានមនុស្ស ដែលជាស្តម្ភមួយក្នុងចំណោមស្តម្ភទាំងបួន នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបី របស់រាជរដ្ឋាភិបាល។ ដើម្បីសម្រេចឱ្យបាននូវការអនុវត្តគោលនយោបាយចក្ខុវិស័យឧត្តមសិក្សា២០៣០ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធានាឱ្យបាន នូវការប្រតិបត្តិនៃការងារ ដូចខាងក្រោម៖

- ការបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- ការបង្កើតក្រុមការងារបច្ចេកទេសឧត្តមសិក្សា និងលេខាធិការដ្ឋាន
- ការយល់ព្រមទៅលើគោលនយោបាយចក្ខុវិស័យឧត្តមសិក្សា២០៣០ ដែលត្រូវធ្វើបន្តដោយការអភិវឌ្ឍផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពឧត្តមសិក្សា ២០១៤-២០១៨។

ក្រសួងពាក់ព័ន្ធ ស្ថាប័នរាជរដ្ឋាភិបាល គ្រឹះស្ថានឧត្តមសិក្សា និងដៃគូរអភិវឌ្ឍន៍ រួមទាំងអង្គការសង្គមស៊ីវិល ត្រូវរួមចំណែកដល់ការផ្សព្វផ្សាយគោលនយោបាយចក្ខុវិស័យឧត្តមសិក្សា២០៣០ និងអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពឧត្តមសិក្សា ២០១៤-២០១៨ ឱ្យទទួលបានជោគជ័យ។